ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

# គម្រោងវិនិយោគក្នុង ឆមាសទី១ ឆ្នាំ២០២៦

ដែលត្រូវបានអនុម័តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

| គម្រោងវិនិយោគ | ទុនវិនិយោគ | បង្កើតការងារ |
|---|---|---|
| ២៧៦ គម្រោង | ៥,៧ ប៊ីលាន ដុល្លារអាម៉េរិក | ~១៦០ពាន់ កន្លែង |

## ទុនវិនិយោគតាមវិស័យ (គិតជាដុល្លារអាម៉េរិក)




## ប្រភពទុនវិនិយោគឈានមុខ

| | |
|---|---|
| ១. កម្ពុជា | ៤១,៧៤% |
| ២. ចិន | ៣៥,៧៥% |
| ៣. សិង្ហបុរី | ១៥,៣៨% |
| ៤. ម៉ាឡេស៊ី | ៤,២៦% |
| ៥. ហូឡង់ | ០,៨៥% |
| ៦. កោះ British Virgin | ០,៤១% |
| ៧. កោះ Marshall | ០,២៥% |
| ៨. កោះ Samoa | ០,២៥% |
| ៩. ជប៉ុន | ០,១៧% |
| ១០. សហរដ្ឋអាម៉េរិក | ០,១៧% |

## របាយគម្រោងវិនិយោគនៅតាមបណ្តារាជធានី-ខេត្ត



ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation-Religion-King

រាជរដ្ឋាភិបាលកម្ពុជា
ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
Council for the Development of Cambodia

*ថ្ងៃអង្គារ ១៥រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០*
*រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៦*

# សេចក្តីប្រកាសព័ត៌មាន

## គម្រោងវិនិយោគចំនួន២៧៦ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ៤,៧ប៊ីលានដុល្លារអាម៉េរិក ត្រូវបានចុះបញ្ជីនៅកម្ពុជា

ក្នុងឆមាសទី១ ឆ្នាំ២០២៦ គម្រោងវិនិយោគដែលត្រូវបានចុះបញ្ជីដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក.) និងអនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត (អ.គ.វ.រ.ខ.) មានចំនួន២៧៦ ក្នុងទំហំទុនវិនិយោគសរុបប្រមាណ៤,៧ប៊ីលានដុល្លារអាម៉េរិក ដែលនឹងអាចបង្កើតការងារបានប្រមាណ១៦០ពាន់កន្លែង។ ក្នុងចំណោមគម្រោងវិនិយោគទាំង២៧៦ មានគម្រោងវិនិយោគចំនួន១៨១ ក្នុងទំហំទុនវិនិយោគប្រមាណ ៤,៤ប៊ីលានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណជាង១២០ពាន់កន្លែង ត្រូវបានចុះបញ្ជីដោយ ក.អ.ក. ដែលក្នុងនោះ គម្រោងវិនិយោគនៅក្រៅតំបន់សេដ្ឋកិច្ចពិសេសមានចំនួន១០៥, គម្រោងបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន៧, និងគម្រោងវិនិយោគនៅក្នុងបណ្តាតំបន់សេដ្ឋកិច្ចពិសេសចំនួន៦៩។ ដោយឡែក គម្រោងវិនិយោគដែលត្រូវបានចុះបញ្ជីដោយ អ.គ.វ.រ.ខ. មានចំនួន៩៥ ក្នុងទំហំទុនវិនិយោគប្រមាណ ២៩១លានដុល្លារអាម៉េរិក និងអាចបង្កើតការងារបានប្រមាណ៣៥ពាន់កន្លែង។

ជាការកត់សម្គាល់ គម្រោងវិនិយោគដែលមានភាពលេចធ្លោជាងគេប្រចាំឆមាសទី១ នេះ រួមមាន៖

### ក.ក្រៅតំបន់សេដ្ឋកិច្ចពិសេស

| | |
|---|---|
| កសិកម្ម និង កសិ-ឧស្សាហកម្ម | **គម្រោងវិនិយោគបង្កើតកសិដ្ឋានចិញ្ចឹម និងបង្កាត់ពូជសត្វស្វា**<br>- **ទីតាំង៖** ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ<br>- **ទុនវិនិយោគប្រមាន៖** ៤០លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ២៨២កន្លែង។<br>**គម្រោងវិនិយោគបង្កើតកសិដ្ឋានដាំដំណាំឈើហូបផ្លែ និងសាងសង់រោងចក្រកែច្នៃ**<br>- **ទីតាំង៖** ស្រុកបាណន់ ខេត្តបាត់ដំបង<br>- **ទុនវិនិយោគប្រមាណ៖** ២០លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ១៧៤កន្លែង។<br>**គម្រោងពង្រីកផលិតកម្ម និងបន្ថែមអគាររោងចក្រកែច្នៃផ្លែស្វាយ, គ្រាប់ស្វាយចន្ទី, ចេក, ខ្នុរ**<br>- **ទីតាំង៖** ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ<br>- **ទុនវិនិយោគប្រមាណ៖** ១៤លានដុល្លារអាម៉េរិក<br>- **បង្កើតការងារ៖** ២.២០១កន្លែង។ |

**ឧស្សាហកម្ម**

**គម្រោងពង្រីកផលិតកម្ម និងបន្ថែមអគារផលិតកម្មរោងចក្រផលិតស៊ីម៉ងត៍**

- **ទីតាំង៖** ស្រុកជងទង់ ខេត្តកំពត
- **ទុនវិនិយោគប្រមាណ៖** ២១០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៥១២កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រជ្រលក់ពណ៌**

- **ទីតាំង៖** ស្រុកទ្រាំង ខេត្តតាកែវ
- **ទុនវិនិយោគប្រមាណ៖** ៤៦លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៣៣០កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតក្រណាត់គ្រប់ប្រភេទ**

- **ទីតាំង៖** ស្រុកកៀនស្វាយ ខេត្តកណ្តាល
- **ទុនវិនិយោគប្រមាណ៖** ២៥លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ១.៨២០កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតមី និងគ្រឿងផ្សំសម្រាប់មី**

- **ទីតាំង៖** ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
- **ទុនវិនិយោគប្រមាណ៖** ២៣លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៨០៤កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតត្រីខកំប៉ុង និងទឹកត្រី**

- **ទីតាំង៖** ស្រុកដំណាក់ចង្អើរ ខេត្តកែប
- **ទុនវិនិយោគប្រមាណ៖** ៧លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ១៧១កន្លែង។

**ទេសចរណ៍**

**គម្រោងវិនិយោគសាងសង់ និងធ្វើអាជីវកម្មសណ្ឋាគារថ្នាក់ផ្កាយ៥ ចំនួន១.៣៤១បន្ទប់**

- **ទីតាំង៖** ក្រុងបាវិត ខេត្តស្វាយរៀង
- **ទុនវិនិយោគប្រមាណ៖** ៣០០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ២.០៦០កន្លែង។

**ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ**

**គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព៣៥០មេហ្គាវ៉ាត់**

- **ទីតាំង៖** ខេត្តពោធិ៍សាត់
- **ទុនវិនិយោគប្រមាណ៖** ២២៦លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៨៨កន្លែង។

**គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់**

- **ទីតាំង៖** ខេត្តមណ្ឌលគិរី
- **ទុនវិនិយោគប្រមាណ៖** ២០០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៤២កន្លែង។

**គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលខ្យល់ អានុភាព១៥០មេហ្គាវ៉ាត់**

- **ទីតាំង៖** ខេត្តមណ្ឌលគិរី
- **ទុនវិនិយោគប្រមាណ៖** ១៨៦លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៣៩កន្លែង។

**គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលជីវម៉ាស អានុភាព៥០មេហ្គាវ៉ាត់ និងស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ អានុភាព៤០មេហ្គាវ៉ាត់**

- **ទីតាំង៖** ស្រុកវាលវែង ខេត្តពោធិ៍សាត់
- **ទុនវិនិយោគប្រមាណ៖** ១៣១លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៥៣៥កន្លែង។

**គម្រោងវិនិយោគអភិវឌ្ឍន៍ស្ថានីយផលិតអគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យអានុភាព២០០មេហ្គាវ៉ាត់**

- **ទីតាំង៖** ស្រុកសេសាន ខេត្តស្ទឹងត្រែង
- **ទុនវិនិយោគប្រមាណ៖** ៣០០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ២.០៦០កន្លែង។

## ខ. ក្នុងតំបន់សេដ្ឋកិច្ចពិសេស

**ឧស្សាហកម្ម**

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតសំបកកង់រថយន្ត និងពោះវៀនកង់**

- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស យូ ប៊ី អ៊ី ស្នួល នៅខេត្តក្រចេះ
- **ទុនវិនិយោគប្រមាណ៖** ៤៥០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៣.៥២៨កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតក្រដាស និងផលិតផលពីក្រដាស**

- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ស៊ីន បារិត នៅខេត្តស្វាយរៀង
- **ទុនវិនិយោគប្រមាណ៖** ៥០លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៤១០កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផ្គុំ និងដំឡើងរថយន្តអគ្គិសនី**

- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ពោធិ៍សាត់ នៅខេត្តពោធិ៍សាត់
- **ទុនវិនិយោគចំនួន៖** ៤៦លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៦១១កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតប្លាស្ទិកក្នុងទម្រង់បឋម (គ្រាប់ជ័រប្លាស្ទិក)**

**ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ពោធិ៍សាត់ នៅខេត្តពោធិ៍សាត់
- **ទុនវិនិយោគប្រមាណ៖** ២៩លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ១៤១កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិតគ្រឿងសង្ហារិមអគ្គិសនី**

- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ នៅខេត្តព្រះសីហនុ
- **ទុនវិនិយោគប្រមាណ៖** ២១លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៣.៥៩០កន្លែង។

**គម្រោងវិនិយោគបង្កើតរោងចក្រផលិត និងកែច្នៃប្រេងសម្រាប់សម្បកកង់យានយន្ត និងប្រេងសម្រាប់ផលិតផលកែច្នៃជ័រកៅស៊ូ**

- **ទីតាំង៖** តំបន់សេដ្ឋកិច្ចពិសេស ស៊ីន បារិត នៅខេត្តស្វាយរៀង
- **ទុនវិនិយោគប្រមាណ៖** ៩,៦លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៣៥០កន្លែង។

**ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ**

**គម្រោងវិនិយោគបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន៧គម្រោង**

- **ទីតាំង៖** រាជធានីភ្នំពេញ (២តំបន់), ខេត្តកំពង់ស្ពឺ (៣តំបន់), ខេត្តកំពត (២តំបន់)
- **ទុនវិនិយោគប្រមាណ៖** ៨៣៧លានដុល្លារអាម៉េរិក
- **បង្កើតការងារ៖** ៤.២០៣កន្លែង។